ភ្នំពេញ ថ្ងៃទី ២៣ ខែមីនា ឆ្នាំ២០១៧

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី

## ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារទទួលជួបសំដែងការគួរសមរបស់ប្រធានតំណាង (Chief Representative) របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA)



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ

នាវេលាម៉ោង ៣:00នាទី រសៀល ថ្ងៃទី២៣ ខែមីនា ឆ្នាំ២០១៧ ឯកឧត្តម **គង់ វិបុល** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានពន្ធដារ បានទទួលជួបសំដែងការគួរសមនិងគោរពលាពីសំណាក់ លោក Adachi Itsu ប្រធានតំណាង (Chief Representative) របស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) ដែលបានបញ្ចប់បេសកកម្មរបស់លោក និងលោក Sugano Yuichi ប្រធានតំណាងថ្មីរបស់ JICA ដែលត្រូវទទួលភារកិច្ចបន្ត ដោយមានការចូលរួមពីសំណាក់ឯកឧត្តម វ៉ាន់ ពុទ្ធិពល អគ្គនាយករង ឯកឧត្តម ហេង សុខណាង អគ្គនាយករង ថ្នាក់ដឹកនាំ មន្ត្រីពន្ធដារពាក់ព័ន្ធ និងអ្នកជំនាញការជំនួយបច្ចេកទេស JICA ប្រចាំនៅ អគ្គនាយកដ្ឋានពន្ធដារផងដែរ។

ក្នុងកិច្ចជំនួបនោះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងតំណាងប្រធាន JICA បានជជែកពិភាក្សា ប្រកបអំពីវឌ្ឍនភាពនៃកិច្ចខិតខំក្នុងការអនុវត្តយ៉ាងម៉ឺងម៉ាត់ ក្នុងការធ្វើកំណែទម្រង់ទាំងផ្នែករដ្ឋបាលសារពើពន្ធ និងគោលនយោបាយសារពើពន្ធ ព្រមទាំងពង្រឹងការអនុវត្តច្បាប់ ស្របតាមយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ (RMS) និងការគ្រប់

គ្រងហិរញ្ញវត្ថុសាធារណៈ (PFM)។ ជាលទ្ធផល ការប្រមូលពន្ធកន្លងមកចាប់ពីឆ្នាំ ២០១២ គឺតែងតែសម្រេចបាន លើសផែនការ ហើយការប្រមូលចំណូលពន្ធបានកើនឡើងជាមធ្យមប្រមាណ ២០% ក្នុងមួយឆ្នាំ ដែលជាក់ស្តែងបានកើនប្រមាណពី ៧៣៦ លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១២ រហូតទទួលបានប្រមាណជាង ១,៤ ពាន់លានដុល្លារអាមេរិក ក្នុងឆ្នាំ២០១៦។ ដោយឡែកសម្រាប់ឆ្នាំ ២០១៧ គោលដៅប្រមូលចំណូលត្រូវសម្រេចឱ្យបានប្រមាណជាង ១,៧ ពាន់លានដុល្លារអាមេរិក និងសម្រាប់ឆ្នាំ ២០១៨ ត្រូវសម្រេចឱ្យបានប្រមាណចន្លោះ ពី ១,៩ពាន់លានដុល្លារ ទៅ ២ ពាន់លានដុល្លារអាមេរិក។

ចាប់តាំងពីឆ្នាំ២00៤រហូតមក គម្រោងជំនួយបច្ចេកទេសរបស់ ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិ នៃប្រទេសជប៉ុន (JICA) ដើរតួនាទីយ៉ាងសារៈសំខាន់ ក្នុងពង្រឹងសមត្ថភាពមន្ត្រីរាជការពន្ធដារ ក្នុងការចូលរួមចំណែកក្នុងការអនុវត្តកំណែទម្រង់ពន្ធដារកម្ពុជា។ អគ្គនាយកដ្ឋានពន្ធដារ និង JICA បានប្តេជ្ញានឹងបន្តកិច្ចសហការអនុវត្តគម្រោងជំនួយ ដែលកំពុងអនុវត្តគឺគម្រោង "The Project for Capacity Development of General Department of Taxation under the framework of PFM reform (Phase 2)" (មានរយៈពេល ៣ ឆ្នាំ ចាប់ពីខែសីហា ឆ្នាំ២០១៥ ដល់ ខែសីហា ឆ្នាំ២០១៨) ដែលផ្តោតលើពង្រឹងសមត្ថភាពរបស់មន្ត្រីក្នុងការធ្វើផែនការ និងតាមដានដើម្បីធ្វើឱ្យសេវាអ្នកជាប់ពន្ធ កាន់តែប្រសើរឡើង, ពង្រឹងការផ្សព្វផ្សាយទាក់ទងនឹង បញ្ជីគណនេយ្យសាមញ្ញ, ៣. ពង្រឹងការអប់រំអំពីពន្ធដារនិងទំនាក់ទំនងសាធារណៈ, ៤. ពង្រឹងសមត្ថភាពក្នុងការរៀបចំកែសម្រួល និងប្រើប្រាស់សំណួរដែលត្រូវបានសួរញឹកញាប់ (FAQs)។

ជាទីបញ្ចប់ ឯកឧត្តម គង់ វិបុល ក៏បានថ្លែងអំណរគុណសាជាថ្មីចំពោះ JICA ដែលតែងគាំទ្រផ្តល់ជំនួយបច្ចេកទេសដល់កម្ពុជា ជាពិសេសសម្រាប់អគ្គនាយកដ្ឋានពន្ធដារ ព្រមទាំងលោក Adachi Itsu ប្រធានតំណាង JICA ដែលបានបញ្ចប់បេសកកម្មរបស់លោក និងស្វាគមន៍លោក Sugano Yuichi ប្រធានតំណាងថ្មីរបស់ JICA ដែលត្រូវទទួលភារកិច្ចបន្ត ហើយជំរុញឱ្យក្រុមការងារ អនុវត្តគម្រោងផ្តល់កិច្ចសហការល្អប្រសើរទៅវិញទៅមក។ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល បានជូនពរលោក Adachi Itsu ត្រលប់ទៅមាតុប្រទេសវិញ ប្រកបដោយសុវត្ថិភាព និងជូនពរលោក Sugano Yuichi ទទួលបានជោគជ័យក្នុងការបំពេញភារកិច្ចថ្មីនេះ៕



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ



© រូបភាពដោយអគ្គនាយកដ្ឋានពន្ធដារ